**ជនពិការ**

- ជនពិការស្ថិតក្នុងហានិភ័យខ្ពស់ខ្លាំងជាងគេពីជំងឺកូវីដ-១៩ ហើយការឆ្លើយតបរបស់រដ្ឋទាំងឡាយចាំបាច់ត្រូវរួមបញ្ចូលវិធានការជាគោលដៅដើម្បីដោះស្រាយបញ្ហាទាំងនោះ។ វិធានការឆ្លើយតបនឹងវិបត្តិការការពារសុខភាព និងសង្គម ត្រូវតែមានសម្រាប់មនុស្សគ្រប់រូប ហើយមិនត្រូវរើសអើងជនពិការឡើយ។
- ការដាក់ឱ្យនៅឃ្លាតឆ្ងាយពីគ្នា និងវិធានការអាសន្នផ្សេងទៀត ចាំបាច់ត្រូវគិតគូរពីតម្រូវការរបស់ជនពិការដែលពឹងផ្អែកលើបណ្តាញគាំទ្រចាំបាច់សម្រាប់ការរស់រានមានជីវិតរបស់ខ្លួន ហើយជនពិការមួយចំនួនក្នុងនោះ អាចមានភាពតានតឹងខ្លាំងក្នុងអារម្មណ៍ដោយសារតែការដាក់បង្ខាំង។
- រដ្ឋទាំងឡាយ គួរដាក់ចេញនូវវិធានការបន្ថែម ដើម្បីធានាឱ្យមានទំនាក់ទំនងជាមួយបណ្តាញគាំទ្រសម្រាប់ជនពិការនៅទូទាំងវិបត្តិទាំងមូល។ នៅពេលដែលការរឹតត្បិតលើការដើរហើររារាំងបណ្តាញគាំទ្រពីគ្រួសារ និងសង្គមដែលមានស្រាប់ ពួកគេគួរទទួលបានជំនួសវិញដោយសេវាផ្សេងទៀត។
- ធានាថាការសម្រេចចិត្តលើលៃលកធនធានដែលកម្រដាក់ជំឡើង (ឧទា. កង្ហារសម្រាប់ឲ្យខ្យល់ចេញចូល) មិនផ្អែកលើការចុះខ្សោយ ឬពិការភាពពីមុន តម្រូវការការគាំទ្រខ្ពស់ ការវាយតំលៃគុណភាពជីវិត ឬភាពលំអៀងខាងវេជ្ជសាស្ត្រទៅលើជនពិការ។
- រដ្ឋទាំងឡាយ គួរដោះលែងជនពិការពីស្ថាប័ន លំនៅដ្ឋានថែទាំសុខភាព អគារផ្នែកវិកលចរិក និងអគារដទៃផ្សេងទៀត ប្រសិនជាអាចធ្វើបាន និងចាត់វិធានការ ដើម្បីធានាការការពារដល់បុគ្គលទាំងឡាយដែលស្ថិតនៅក្នុងអគារទាំងនោះ។
- ការទទួលបានជំនួយហិរញ្ញវត្ថុបន្ថែម និងការគាំពារសង្គម គឺមានសារៈសំខាន់ណាស់សម្រាប់ជនពិការ និងគ្រួសាររបស់ពួកគេ ដោយសារពួកគេភាគច្រើនពឹងផ្អែកលើសេវា ដែលត្រូវបានផ្អាក ហើយអាចនឹងខ្វះធនធានសម្រាប់បំពេញសេចក្តីត្រូវការមូលដ្ឋានរបស់ខ្លួន។